**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

HANA Microelectronics (Cambodia) Co., Ltd.
សមាជិក ហាណា ម៉ាយក្រូអេឡិចត្រូនិក គ្រុប

# កំណត់ហេតុប្រជុំកិច្ចព្រមព្រៀងរវាង

## តំណាងក្រុមហ៊ុនហាណា ជាមួយប្រតិនិធិបុគ្គលិកទាំង ០៨ រូប រួមទាំងកម្មករ កម្មការនី ក្នុងការព្យួរការងារបណ្តោះអាសន្ន

ឆ្នាំពីរពាន់ម្ភៃបួន ខែ មីនា ថ្ងៃទី ២៥ វេលាម៉ោង ប្រាំបួន ព្រឹក នៅការិយាល័យរបស់ក្រុមហ៊ុនហាណា ម៉ាយក្រូអេឡិចត្រូនិកបានរៀបចំកិច្ចប្រជុំមួយដែលប្រព្រឹត្តទៅ ក្រោមអធិបតីភាពរបស់ លោក PRATHUANG PANKHAM ប្រធានគ្រប់គ្រងផ្នែកផលិត និង ធនធានមនុស្ស និង លោក ហ៊ន បូរី ប្រធានផ្នែកនាំចេញ លោក NARHIT MUANGNAKIN ប្រធានគ្រប់គ្រងផ្នែកគុណភាព និង កញ្ញា គឹម មន្ថា ប្រធានផ្នែកធនធានមនុស្ស របស់ក្រុមហ៊ុន ហាណា ម៉ាយក្រូអេឡិចត្រូនិក។

ការប្រព្រឹត្តនៅក្នុងអង្គប្រជុំ:

**របៀបវារៈ១៖ ការបើកអង្គប្រជុំ និង សំណេះសំណាល**

លោកប្រធានអង្គប្រជុំ បានជួបសំណេះសំណាល ក៏ដូចជាសួរសុខទុក្ខទៅកាន់ប្រតិភូបុគ្គលិកទាំងអស់ និង ប្រធានផ្នែក ក៏ដូចជាបុគ្គលិកដែលមានវត្តមាន ប្រាប់ពីគោលបំណងនៃអង្គប្រជុំ បន្ទាប់ពីជួបសំណេះសំណាលរួចលោកបានប្រកាសអង្គប្រជុំ តែម្តង។

**របៀបវារៈ២៖ ការពិភាក្សាអំពីកិច្ចព្រមព្រៀងនៃការឈប់សម្រាកបណ្តោះអាសន្ន**

លក្ខខណ្ឌនៃការធ្វើឈប់សម្រាកបណ្តោះអាសន្ន

**ប្រការ១៖** ការព្យួរការងារបណ្តោះអាសន្ន ៖

- ផ្នែក MACOM ចំនួន ៣៥នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប ២៤០នាក់ ចាប់ពីថ្ងៃទី ២ ខែមេសា ឆ្នាំ ២០២៤ រហូត ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០២៤ ។ ដោយសារស្ថានភាពបច្ចុប្បន្នការផលិតមានការថយចុះធ្លាក់ការបញ្ជាទិញពីអតិថិជនផ្សេងៗ ដោយសារវិបត្តិសកល និង លែងមានការបញ្ជាទិញពីអតិថិជន Macom តទៅទៀត ដោយការព្យួរការងារបណ្តោះអាសន្នរយៈ ២ខែនេះ ដើម្បីត្រៀមរង់ចាំការងារពីអតិថិជនថ្មីបន្តទៀត ដែលបាននឹងកំពុងចចារជាមួយក្រុមហ៊ុនរួចហើយ ហើយនឹងដាក់ការបញ្ជានាពេលខាងមុខនេះ ។

**ប្រការ២៖** ក្នុងកំឡុងពេលព្យួរការងារបណ្តោះអាសន្ននេះ ក្រុមហ៊ុនបានផ្តល់ជូនប្រាក់ឧបត្ថម្ភ ជូនកម្មករនិយោជិតដូចខាងក្រោម៖

- ប្រាក់ឧបត្ថម្ភ ៥០% នៃប្រាក់ឈ្នួលគោល
- ប្រាក់ឧស្សាហ៍ ១០០ %
- ប្រាក់ឧបត្ថមស្នាក់នៅ ១០០ %

ដោយការបើកប្រាក់ឧបត្ថម្ភលើកទី១នៅថ្ងៃទី១៤ និង លើកទី២នៅថ្ងៃ ទី២៨នៃខែនីមួយៗ ការបើកប្រាក់ឧបត្ថម្ភនេះគឺបើកជូន២ដងក្នុងមួយខែ ។

**ប្រការ៣៖** យោងតាមច្បាប់ការងារមាត្រាទី ៧១ និង មាត្រាទី៧២ ដើម្បីរក្សាបានស្ថេរភាពក្នុងក្រុមហ៊ុនបាន និង ជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់បុគ្គលិកបានសមរម្យ ក្រុមហ៊ុនផ្តល់ជូនប្រាក់ឈ្នួល និង អត្ថប្រយោជន៍ ។

**របៀបវារៈ៣ សំណួរ របស់បងប្អូនប្រតិភូបុគ្គលិក និង ការប្រកាសបិទអង្គប្រជុំ**

ប្រតិភូបុគ្គលិក លោក ដួង គឹមម៉េង លោកស្រី រដ្ឋ ធានី និង ឈុំ ស៊ីណា សូមអោយភាគី តំណាងក្រុមហ៊ុន ជួយបញ្ជាក់បន្ថែមពីអត្ថប្រយោជន៍កម្មករនិយោជិត និង សិទ្ធិដែលពួកគាត់អាច ទទួលបានក្នុងកំឡុងពេលឈប់សម្រាកបណ្តោះអាសន្ន ។

ដោយមានសំណួរបញ្ជាក់បន្ថែម ភាគីតំណាងនិយោជក កញ្ញាគឹម មន្ថា ដែលជាប្រធានផ្នែកធនធានមនុស្សបានធ្វើការបកស្រាយនិងពន្យល់លំអិតពីការផ្តល់ជូនប្រាក់ឧបត្ថម្ភ៥០%នៃប្រាក់ឈ្នួលគោល និង ធ្វើការបញ្ជាក់ពីលក្ខខណ្ឌដែលកម្មករនិយោជិតត្រូវទទួលបាន ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងម្ភៃ នាទីព្រឹក ក្រោមបរិយាកាសដ៏ស្និទ្ធស្នាល និងទទួលបានលទ្ធផលល្អប្រសើរ ។

| អ្នកធ្វើរបាយការណ៍ | អ្នកទទួលជ្រាប | អ្នកទទួលជ្រាប |
|---|---|---|
| លោក ឡុង វុត្ថា | លោក ដួង គឹមម៉េង | លោក Prathuang Pankham |
| បុគ្គលិកផ្នែកធនធានមនុស្ស | ប្រធានប្រតិភូបុគ្គលិក | ជ.នាយកក្រុមហ៊ុន |

ក្រុមហ៊ុន ហាណា មៃក្រូអេឡិចត្រូនិក (ខេមបូឌា) HANA MICROELECTRONICS (CAMBODIA) CO., LTD. KINGDOM OF CAMBODIA

ភ្ជាប់មកជាមួយនូវៈ

បញ្ជីអវត្តមាន

ចំលងជូនៈ

- គ្រប់ប្រធានផ្នែក
- សមាជិក អង្គប្រជុំ ដើម្បីអភិវឌ្ឍន៍
- ឯកសារ កាលប្បវត្តិ

**ក្រុមហ៊ុនហាណាម៉ាយក្រូអេឡិកត្រូនិក (ខេមបូឌា) ខូអិលធីឌី**

កោះកុងថ្ងៃទី ....២៥.... ខែ .....មីនា.... ឆ្នាំ ២០២៤

## <u>សេចក្តីបញ្ជាក់</u>

យើងខ្ញុំជាប្រតិភូបុគ្គលិកនៃ ក្រុមហ៊ុនហាណា បានពិនិត្យ និងយល់ឃើញថា ក្នុងក្រុមហ៊ុនហាណា ពិតជាមានតម្រូវការចាំបាច់អោយកម្មករ កម្មការនី និងនិយោជិតមួយចំនួន ព្យួរការងារបណ្តោះអាសន្ន ដោយយោងតាមស្ថានភាពបច្ចុប្បន្នការផលិតមានការថយចុះ ដែលធ្វើអោយមានការប៉ះពាល់ដល់ដំណើរផលិតចាប់ពី ខែមេសា ដល់ ឧសភា ឆ្នាំ២០២៤ និង មិនមានការបញ្ជាទិញពីអតិថិជន Macom ទៀតទេ ។

ដើម្បីគ្រប់គ្រងស្ថានភាពសេដ្ឋកិច្ចក្រុមហ៊ុនអោយមានស្ថេរភាព និង ដើម្បីរក្សាស្ថានភាពជីវភាពរបស់កម្មករនិយោជិតអោយបានសមរម្យដើម្បីរង់ចាំការងារបញ្ជាទិញរបស់អតិថិជន ដោយក្រុមហ៊ុនបានផ្តល់ប្រាក់ឧបត្ថម្ភដូចបានរៀបរាប់ខាងក្រោម ៖

- ប្រាក់ឧបត្ថម្ភ ៥០% នៃប្រាក់ឈ្នួលគោល
- ប្រាក់ឧស្សាហ៍ ១០០%
- ប្រាក់ឧបត្ថម្ភស្នាក់នៅ ១០០%

យើងខ្ញុំទាំងអស់គ្នាបានឯកភាពតាមសំណើររបស់ លោកនាយកក្រុមហ៊ុនហាណា ម៉ាយក្រូអេឡិកត្រូនិក ហើយសូមបញ្ជាក់ថាកម្មករ កម្មការនី និងនិយោជិត យល់ព្រមតាមការស្នើសុំរបស់ក្រុមហ៊ុនដោយយោងតាមសេចក្តីបញ្ជាក់ពីស្ថានភាពរបស់ក្រុមហ៊ុនដូចបានរៀបរាប់ខាងលើ ។

ក្រែងពុំពិតប្រាកដ យើងខ្ញុំសូមផ្តិតមេដៃទុកជាភស្តុតាង។

**ប្រតិភូតំណាងបុគ្គលិក**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន ហាណា
ម៉ាយក្រូអេឡិកត្រូនិក (ខេមបូឌា)
HANA MICROELECTRONICS
(CAMBODIA) CO., LTD.
KINGDOM OF CAMBODIA